# ពុទ្ធិកសមាគមខ្មែរ, ឥង្ក.

The Cambodian Buddhist Society, Inc.

13800 New Hampshire Avenue, Silver Spring, MD 20904

Tel: (301) 622-6544

សូមជម្រាបមក លោកយាយ លោកតា លោកមីង លោកមា លោក អ្នកនាង ជាពុទ្ធបរិស័ទ

សូមជ្រាប ។

កម្មវត្ថុ៖ ការបន្តសមាជិកភាព

ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក. សូមរំឭកថា សមាជិកភាពរបស់ពុទ្ធបរិស័ទជាច្រើនបានដាច់កន្លងទៅហើយ ក្រោយពីដាច់ឆ្នាំ ២០០២ នេះ ។ បើសិនជាសមាជិកណាបានបង់វិភាគទាន បន្តសមាជិកភាពរួចហើយ យើងខ្ញុំសូមអរគុណ និងសូមមេត្តាបំភ្លេចនូវលិខិតនេះផងចុះ ។ ប៉ុន្តែបើសិនជា លោក អ្នកនាង មិនទាន់បានបន្តនូវសមាជិកភាពនៅឡើយទេ សូមមេត្តាផ្ញើវិភាគទានប្រចាំខែ-ឆ្នាំមកវត្ត តាមស្រោមសំបុត្រភ្ជាប់មកជាមួយនេះស្រាប់ ។ សូមមេត្តាកុំបារម្ភខ្លាចបង់វិភាគទានលើសពីថ្ងៃខែដែលត្រូវដាច់ យើងខ្ញុំនឹងបន្តសមាជិកភាពចាប់តាំងពីថ្ងៃខែដាច់តទៅ ។

ម្យ៉ាងទៀត បើសិនជាពុទ្ធបរិស័ទណាមិនទាន់ជាសមាជិកនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក. នៅឡើយ ហើយចង់ចូលជាសមាជិក សូមមេត្តាធ្វើសំបុត្រសុំចូលជាសមាជិកមកវត្ត ដោយបញ្ជាក់នូវនាមត្រកូលនិងនាមខ្លួន អាស័យដ្ឋាន ព្រមទាំងលេខទូរស័ព្ទ ជាមួយនឹងវិភាគទានប្រចាំខែ-ឆ្នាំ តាមកម្លាំងសទ្ធានិងសេចក្តីជ្រះថ្លា ឥតមានកំណត់ ។

យើងខ្ញុំសូមកត់សំគាល់ថា ការចូលជាសមាជិកនៃពុទ្ធិកសមាគមខ្មែរ,ឥង្ក. មានសារៈសំខាន់ណាស់ ក្នុងការទាក់ទងជាមួយរដ្ឋាភិបាលអាមេរិកាំង និងក្នុងការរីកចំរើនដល់វត្តពុទ្ធិការាម ដល់សហគមន៍ខ្មែរនៅតំបន់វ៉ាស៊ិងតុន, ឌី.ស៊ី. និងដល់សហគមន៍ខ្មែរទាំងមូលនៅសហរដ្ឋអាមេរិក ។ សព្វថ្ងៃនេះ សូម្បីតែពុទ្ធបរិស័ទចំណុះជើងវត្តដ៏ច្រើនមកធ្វើបុណ្យមែន ពុទ្ធបរិស័ទដែលចូលជាសមាជិកមានចំនួនតិចតួចណាស់ មិនអាចឲ្យគេចាប់អារម្មណ៍បានឡើយ ។ ម្យ៉ាងទៀត តាមលក្ខន្តិកៈនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក. មានតែសមាជិកទេដែលអាចចូលប្រជុំក្នុងមហាសន្និបាតបានមានសិទ្ធិបោះឆ្នោតនិងឈរឈ្មោះជាបេក្ខជនបាន ។

សូមអរគុណ ។

ធ្វើនៅវត្តពុទ្ធិការាម ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៣

ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក.

តំបន់វ៉ាស៊ិងតុន ឌី.ស៊ី.

ពុទ្ធិកសមាគមខ្មែរ,ឥង្ក.
The Cambodian Buddhist Society, Inc.
13800 New Hampshire Avenue, Silver Spring, MD 20904
Tel: (301) 622-6544

January 1, 2003

Dear Sir/Madam:

<u>Subject</u>: Renewal of Membership

The Board of Directors of the Cambodian Buddhist Society, Inc. would like to inform that membership of several members has expired since the end of the year 2002. If you have renewed your membership and paid your due, we wish to thank you and request that you disregard this notice. However, if you have not renewed your membership, please pay your due by including your payment in the enclosed envelope. Please do not worry about renewing your membership even if it is not yet due. We extend your membership from the expiration date.

For those who have not yet enrolled and wish to become members, please file a letter of application by stating your family name and given name, your address, and your telephone number. The letter should be sent along with a payment of due to the Cambodian Temple in the enclosed envelope.

It is very important for you to become a member. The Cambodian Buddhist Society, Inc. needs you as member to promote its growth and its dealing with the American Government for the benefits of the Cambodian community in the Washington DC area and all the Cambodian communities in the United States. Even though a large number of Cambodians come to the Temple for celebration, only a minimal fraction of the Cambodians are members. Furthermore, according to the by-laws, only members are allowed to attend the General Assembly, to vote, and to be candidates in the election.

Thank you.

The Board of Directors of
the Cambodian Buddhists Society, Inc.
of Washington DC area